# ត្រីសមុទ្រខុសច្បាប់...

ការមានត្រីប្រភេទទាំងនេះ នៅក្នុងសហរដ្ឋអាមេរិក គឺជាការខុសច្បាប់ :







ការមានត្រីប្រភេទទាំងនេះ នៅកន្លែងខ្លះក្នុងភាគឦសាននៃសហរដ្ឋអាមេរិក ដោយពុំមានសំបុត្រអនុញ្ញាត គឺជាការខុសច្បាប់ :

- **ត្រីគល់រាំងខ្មៅ** (ខុសច្បាប់នៅក្នុង CT, ME, & NY)
- **ត្រីគល់រាំងស្មៅ** ឬ **ត្រីកល់រាំងស** (ខុសច្បាប់នៅក្នុង CT, MA, ME, & NH)
- **ត្រីគល់រាំងទឹកប្រាក់** (ខុសច្បាប់នៅក្នុង CT, ME, & NY)
- **ត្រីគល់រាំងក្បាលធំ** (ខុសច្បាប់នៅក្នុង CT, ME, & NY នៅខាងក្រៅ NYC និងខោនធី Westchester)

ការមាន**ក្តាមចិនឥតម្រាម** នៅក្នុងសហរដ្ឋអាមេរិក ក៏ជាការខុសច្បាប់ដែរ ។

តើមានអ្វីកើតឡើង ចំពោះអ្នកដែលនាំចូល នូវត្រីសមុទ្រដែលខុសច្បាប់?

- នៅក្នុងឆ្នាំ 2002 បុរសម្នាក់នៅក្រុង New York ត្រូវបានឲ្យជាប់គុកចំនួន 3 ខែ និងបានផាក $3,000 សំរាប់ការនាំចូលនូវក្តាមចិនឥតម្រាម ។
- នៅក្នុងឆ្នាំ 2005 បុរសម្នាក់នៅក្រុង Los Angeles ត្រូវបានផាក $230,000 សំរាប់ការនាំចូល និងការលក់ត្រីក្បាលពស់រស់ ។

# ផលវិបាក...

ការព្រលែងត្រីសមុទ្ររស់ :

- **អស់ប្រាក់កាស!**
  នៅក្នុងឆ្នាំ 2002 រដ្ឋ Maryland បានចំណាយប្រាក់អស់ប្រហែល $50,000 ដើម្បីយកត្រីក្បាលពស់ ចេញតែពីត្រពាំងប៉ុណ្ណោះ ។
- **ចំឡងជំងឺទៅមនុស្ស និងសត្វ!**
  អាសន្នរោគ ជាជំងឺម្យ៉ាងរបស់មនុស្ស ដែលបណ្តាលឲ្យរាកអាចម៍យ៉ាងខ្លាំងខ្លា ហើយជាញឹកញយបណ្តាលឲ្យស្លាប់ ត្រូវបានគេរកឃើញនៅក្នុងអាងចិញ្ចឹមត្រីសមុទ្រជាច្រើន នៅក្នុងហុងកុង ។
- **ប៉ះពាល់ដល់សត្វនិងដំណាំ ជាកំណើតដើមក្នុងស្រុក!**
  ក្តាមចិនឥតម្រាម ស៊ីដំណាំទឹកប្រៃ ស៊ីត្រីសាលម៉ុន និងពងត្រីបាឡែន ស៊ីបង្កងបង្គារ និងស៊ីកូនត្រី ។
- **គឺជាអំពើខុសច្បាប់!**
  ការព្រលែងត្រីរស់ និងអណ្តើករស់ ដែលមិនមែនជាកំណើតដើមនៅក្នុងស្រុក ទៅក្នុងព្រៃរនាមគឺជាការខុសច្បាប់ ។ បើសិនជានគរបាលចាប់បាន អ្នកនឹងត្រូវបានផាក ឬបញ្ជូនឲ្យទៅចូលគុក ។

MIT Sea Grant

Funded by NOAA's National Sea Grant Program.
Grant # NA86RG0074

សំរាប់ពត៌មានបន្ថែម...

មើល : http://massbay.mit.edu/seafood
អ៊ីម៉ែល : seafood@mit.edu
ទូរស័ព្ទ : 617-253-7092
សំបុត្រ : MIT Sea Grant College Program
Center for Coastal Resources
77 Massachusetts Ave. E38-300
Cambridge, MA 02139

This guide is available in Chinese, English, Khmer, Korean, Spanish, and Vietnamese. Please contact the MIT Sea Grant College Program for free copies.

MITSG Publication # 06-2/KHMER

# ត្រីសមុទ្ររស់ និងស្រស់ : ចូលទៅក្នុងឆ្នាំងខ្លះ មិនមែនចូលទៅក្នុងព្រៃរនាមឡើយ



ត្រូវបរិភោគត្រីសមុទ្ររបស់អ្នក គឺមិនត្រូវព្រលែងវាឡើយ ។

ត្រូវដាក់សំណល់ត្រីសមុទ្រ ចូលទៅក្នុងធុងសំរាម ។

ត្រូវប្រុងប្រយ័ត្នថែមទៀត ចំពោះត្រីសមុទ្រដែលមិនមែនជាកំណើតដើមក្នុងស្រុក ។

*ត្រីសមុទ្រ គឺសំដៅទៅលើសត្វទឹកសាប ទឹកប្រៃ និងដំណាំទាំងអស់ដែលអាចបរិភោគបាន ។

# ត្រូវបរិភោគត្រីសមុទ្ររបស់អ្នក គឺមិនត្រូវព្រលែងវាឡើយ...

**ហេតុអ្វី?** បើត្រីសមុទ្ររស់ ដែលមិនមែនជាកំណើតដើមក្នុងស្រុកត្រូវបានព្រលែង វាបណ្តាលមានបញ្ហា ពីព្រោះវាស៊ីដំណាំ និងសត្វនានា ដូចជាត្រីដែលមនុស្សបរិភោគ ។ ត្រូវបង្កកត្រីសមុទ្ររស់ដែលនៅសល់ ឬដាក់វាទៅក្នុងធុងសំរាម គឺមិនត្រូវព្រលែងវាឡើយ ។ ការព្រលែងត្រី និងអណ្តើករស់ ដែលមិនមែនជាកំណើតដើមក្នុងស្រុក ទៅក្នុងព្រៃ គឺជាការខុសច្បាប់ ។





# ត្រូវដាក់សំណល់ត្រីសមុទ្រ ចូលទៅក្នុងធុងសំរាម...



**ហេតុអ្វី?** ត្រីសមុទ្ររស់និងស្រស់ទាំងអស់ និងកាកសំណល់នៃ ត្រីសមុទ្រ មានជំងឺ និងមេរោគប៉ារ៉ាស៊ីត ដែលអាចឆ្លងទៅសត្វដទៃ ឬមនុស្ស ។ ក្បាលត្រី ស្រកាត្រី ពោះវៀន និងសំបក ត្រូវតែបាន ដាក់ទៅក្នុងធុងសំរាម ។ មិនត្រូវចោលសំណល់ត្រីសមុទ្រទៅក្នុងលូបង្ហូរទឹកតាមផ្លូវថ្នល់ តាមស្ទឹង បឹង ឬមហាសមុទ្រសោះឡើយ។

# ត្រូវប្រុងប្រយ័ត្នថែមទៀត ចំពោះត្រីសមុទ្រ ឥតដើមកំណើតក្នុងស្រុក...

**ហេតុអ្វី?** ការព្រលែង ឬចោលត្រីសមុទ្រដែលមិនមែនជាកំណើតដើមក្នុងស្រុក ក្រៅពីត្រីសមុទ្រមានកំណើតក្នុងស្រុក អាចឲ្យមានគ្រោះថ្នាក់ខ្លាំងជាង ។ ប្រភេទត្រីសមុទ្រដែលមិនមែនជាកំណើតដើមក្នុងស្រុក ឃើញមាននៅតាមហាងលក់ម្ហូបជាញឹកញយ គឺ :



អន្ទង់



ត្រីឆ្លាំង



ត្រីគល់រាំង



រុក្ខជាតិដុះក្នុងទឹក



ក្តាម



លាស
និង ងាវ



អណ្តើក